## ២.៣ ការចូលរៀន គុណភាព និង ប្រសិទ្ធភាពនៅបឋមសិក្សា

### វត្ថុបំណង និង យុត្តិកម្ម

ផលសម្រេចនៃកម្មវិធីនេះ នឹងជួយលើកកំពស់ការចូលរៀន គុណភាព និង ប្រសិទ្ធភាពអប់រំ តាមរយៈបន្តបង្កើនការគាំទ្ររបស់រាជរដ្ឋាភិបាល ចំពោះថវិកាដំណើរការសាលារៀន ទន្ទឹមនឹងការផ្តល់សម្ភារៈបង្រៀន (PAP8) និងពង្រីកកម្មវិធីសាលាកុមារមេត្រី ។

### អាំងឌីកាទ័រ និង ចំណុចដៅ

- អត្រាពិតចូលរៀនថ្មីកើនពី ៨១.00% (ឆ្នាំសិក្សា ២០០៤/០៥) ទៅ ៩៥.00% នៅឆ្នាំ ២០១០។
- អត្រាពិតនៃការសិក្សានៅបឋមសិក្សា កើនពី ៩១.៩០% (ឆ្នាំសិក្សា២០០៤/០៥) ដល់ ៩៦.00% នៅឆ្នាំ ២០១០ ។
- អត្រាបញ្ចប់បឋមសិក្សា កើនពី ៤៦.៧៧% (ឆ្នាំសិក្សា២០០៤/០៥) ដល់ ១00% នៅឆ្នាំ២០១០។
- សាលាបឋមសិក្សាយ៉ាងតិច ៧0% ក្នុងខេត្តនីមួយៗ ជាសាលាកុមារមេត្រី នៅឆ្នាំ២០១០ ។

### យុទ្ធសាស្រ្ត និង វិសាលភាព

កម្មវិធីនេះនឹងជួយបង្កើនតម្លាភាព និង គណនេយ្យភាពដល់សាលាបឋមសិក្សា តាមរយៈការដាក់អោយអនុវត្តប្រព័ន្ធពិនិត្យតាមដានការបំពេញការងាររបស់សាលារៀន និងរបាយការណ៍បំពេញការងាររបស់ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ទន្ទឹមនឹងការពង្រឹងយន្តការសម្របសម្រួលការងារអធិការកិច្ច និង ការគាំទ្រ ព្រមទាំងការពង្រឹងគោលនយោបាយកម្មវិធីអប់រំបញ្ចូលគ្នា ដើម្បីធានាដល់ការចូលរៀនប្រកបដោយសមធម៌ ។

កម្មវិធីនេះនឹងផ្តោតការយកចិត្តទុកដាក់ដល់ការចូលរៀនប្រកបដោយសមធម៌ ពិសេសកុមារី និង កុមារដែលជួបការលំបាក ដូចជាកុមារពិការ កុមារជនជាតិភាគតិច កុមារដែលរស់នៅក្នុងតំបន់ជួបការលំបាក ដែលរួមមានតំបន់ជាប់ព្រំដែន និងតំបន់ដាច់ស្រយាល ។

### កម្មវិធី និងសកម្មភាពចម្បងៗ

- បង្កើនការផ្តល់ថវិកាដំណើរការសាលារៀនទៅទូទាំងប្រទេស ដោយផ្អែកលើការកែប្រែកញ្ចប់ថវិកា និងរូបមន្តបែងចែកថវិកាសម្រាប់សិស្សម្នាក់ ។
- ពង្រឹង និងពង្រីកកម្មវិធីសាលាកុមារមេត្រី ដោយកែលំអការគ្រប់គ្រងសាលារៀន ថ្នាក់អប់រំបញ្ចូលគ្នា ថ្នាក់អប់រំពិសេស ថ្នាក់គួប ថ្នាក់ពីរភាសា កំណែលំអកម្មវិធីសិក្សា និង ស្តង់ដាសិក្សាអប្បបរមា បណ្ណាល័យ និងកម្មវិធីបំណិនជីវិតនៅតាមមូលដ្ឋាន ដូចជាការប្រយុទ្ធប្រឆាំងនឹង HIV/AIDS និង បញ្ហាផ្សេងៗទៀតដែលប៉ះពាល់ដល់សុខភាព ។

- ផ្តល់បន្ទប់រៀនសម្រាប់បំណិនជីវិត ស្ថិតក្រោមកម្មវិធីមេរោគហ៊ីវ/ជម្ងឺអេដស៍ របស់ក្រសួងអប់រំ យុវជន និងកីឡា ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន[១] ។
- ពង្រឹង/កែលំអគុណភាពអប់រំនៅបឋមសិក្សានៅតាមតំបន់ព្រំដែន តំបន់ដាច់ស្រយាល និង តំបន់ជួបការលំបាក តាមរយៈការផ្តល់អាទិភាពលើការផ្តល់សម្ភារបរិក្ខារ ការផ្តល់រង្វាន់លើកទឹកចិត្ត ដល់គ្រូបង្រៀនអោយខ្ពស់ជាងគេ និង ការពិនិត្យតាមដានអោយបានញឹកញាប់ នៅតាមសាលារៀនក្នុងតំបន់ទាំងនោះ ។
- កែលំអកម្មវិធីបំប៉នសិស្សខ្សោយ ដើម្បីជួយដល់សិស្សខ្សោយនៅក្នុងឆ្នាំសិក្សា ជួយជាប្រចាំនៅក្នុងថ្នាក់រៀន និងអនុវត្តកម្មវិធីត្រៀមចូលរៀនថ្នាក់ទី ១ សម្រាប់សិស្សដែលមិនបានឆ្លងកាត់ថ្នាក់មត្តេយ្យ ពង្រឹងសកម្មភាពបង្រៀនក្នុងការជួយសិស្សខ្សោយ ។
- ផ្តល់ថវិកាដល់សាលារៀនសម្រាប់ទិញសៀវភៅសិក្សាគោល ដើម្បីរក្សាអោយបានផលធៀបសិស្ស-សៀវភៅ ១:១ ។
- ពង្រឹងការពិនិត្យតាមដាន តាមរយៈចំណាយប្រតិបត្តិការសម្រាប់មន្ត្រី មន្ទីរខេត្ត-ក្រុង ការិយាល័យអប់រំ ស្រុក-ខ័ណ្ឌ កំរងសាលារៀន ដើម្បីជួយគាំទ្រដល់ការកសាងផែនការ ការគ្រប់គ្រង និងការពិនិត្យតាមដាន ។
- កែលំអប្រព័ន្ធប្រមូលទិន្នន័យ និង របាយការណ៍អប់រំបឋមសិក្សា ពីថ្នាក់សាលារៀន ទៅរដ្ឋបាលកណ្តាល និងពីរដ្ឋបាលកណ្តាលទៅដល់ថ្នាក់សាលារៀន ។

### ការគ្រប់គ្រង និងការពិនិត្យតាមដានកម្មវិធី

នាយកដ្ឋានបឋមសិក្សាគ្រប់គ្រងការពិនិត្យតាមដានកម្មវិធីនេះ ។ ការពិនិត្យតាមដានការរីកចំរើនជាទៀងទាត់ ជាទំនួលខុសត្រូវរបស់ក្រុមអធិការកិច្ចបឋមសិក្សា និងអ្នកត្រួតពិនិត្យរបស់មន្ទីរអប់រំខេត្ត-ក្រុង ការិយាល័យអប់រំស្រុក-ខ័ណ្ឌ ស្របទៅតាមផែនការការងារ និងផែនការអភិវឌ្ឍន៍សាលារៀនដែលបានឯកភាព ។

BMCs ទាំង ១៨៥ ស្រុក-ខ័ណ្ឌ គ្រប់គ្រងថវិការបស់កម្មវិធីនេះ និងបើកផ្តល់សាច់ប្រាក់ទៅអោយសាលារៀន ។ ការពិនិត្យតាមដានវឌ្ឍនភាពនៃចំណាយសាច់ប្រាក់ ជាទំនួលខុសត្រូវរបស់សមាជិក BMCs ដែលបានតែងតាំង ។ BMCs ស្រុក-ខ័ណ្ឌនីមួយៗ ត្រូវធ្វើរបាយការណ៍ប្រចាំខែជូនដល់ BMCs ខេត្ត-ក្រុង ស្តីពីសកម្មភាពបច្ចេកទេស និងស្ថានភាពហិរញ្ញវត្ថុរបស់កម្មវិធី ។ ការបែងចែកថវិកាសម្រាប់កម្មវិធីនេះត្រូវបានផ្តល់ដល់កំរងសាលារៀន សម្រាប់ជួយឧបត្ថម្ភក្នុងការពិនិត្យតាមដាន និងការគាំទ្រសាលារៀន ។

BMCs មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ទទួលខុសត្រូវក្នុងការពិនិត្យតាមដានលទ្ធផល និងការរីកចម្រើនទូទៅនៃសកម្មភាពផ្នែកបច្ចេកទេស និងការផ្តល់ហិរញ្ញប្បទានរបស់កម្មវិធី កែលំអកំហុសឆ្គងពេលចាំបាច់

---

[១] *មានការគាំទ្រ តាមរយៈគណៈកម្មការអន្តរនាយកដ្ឋានស្តីពីមេរោគហ៊ីវ/ជម្ងឺអេដស៍ (ICHA)*

និងធានាការបញ្ជូនរបាយការណ៍ប្រចាំខែទាន់ពេលវេលារបស់ BMCs ការិយាល័យអប់រំ យុវជន និងកីឡាស្រុក-ខ័ណ្ឌ ។ BMCs ខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាសជូន BMCs នាយកដ្ឋានបឋមសិក្សា ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ។

### ផែនការហិរញ្ញវត្ថុ

*តារាងទី៣ : ផែនការហិរញ្ញវត្ថុសម្រាប់ការចូលរៀន ប្រសិទ្ធភាព និងគុណភាពអប់រំបឋមសិក្សា*

| **សកម្មភាព** | **ចំណាយគិតជាលានរៀល** | | | | |
|---|---|---|---|---|---|
| | **2006** | **2007** | **2008** | **2009** | **2010** |
| ១.ថវិកាដំណើការសាលារៀន | 24,500 | 25,500 | 27,000 | 28,000 | 28,000 |
| ២. ការពង្រឹងសកម្មភាពរៀន និងបង្រៀន | 14,500 | 14,500 | 14,600 | 15,600 | 15,600 |
| ៣.ការពង្រឹងការពិនិត្យតាមដានកម្មវិធី | 2,600 | 2,600 | 2,500 | 3,500 | 3,500 |
| **ធនធានសរុប** | **41,600** | **42,600** | **44,100** | **47,100** | **47,100** |

### តម្រូវការអភិវឌ្ឍន៍សមត្ថភាព

- គាំទ្រដល់ការពង្រឹងសមត្ថភាពពិនិត្យតាមដានថវិកាដំណើរការសាលារៀន ដល់មន្ត្រីថ្នាក់រដ្ឋបាលកណ្តាល ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងកំរងសាលារៀន ដើម្បីកែលំអការរៀបចំផែនការ ការគ្រប់គ្រង និងពិនិត្យតាមដានសកម្មភាពនានា និងការចំណាយប្រតិបត្តិ ។
- គាំទ្រដល់ការបង្កើត និងពង្រឹងក្រុមសម្របសម្រួលថ្នាក់ស្រុក-ខ័ណ្ឌ ដែលនឹងទទួលខុសត្រូវជួយកំរងសាលារៀន នៅក្នុងការអនុវត្តការពិនិត្យតាមដានតាមបែបវិមជ្ឈការ លើការបំពេញការងាររបស់សាលារៀន ។
- គាំទ្រដល់ការពង្រឹងប្រព័ន្ធអធិការកិច្ចនៅគ្រប់លំដាប់ថ្នាក់ រួមទាំងពង្រឹងសមត្ថភាពអធិការក្នុងការធ្វើអធិការកិច្ច ប្រព័ន្ធធ្វើរបាយការណ៍ និងព័ត៌មានត្រឡប់ ដើម្បីអោយសាលារៀន និងគ្រូបង្រៀន ឆ្លើយតបទៅនឹងរបាយការណ៍អធិការកិច្ច ព្រមទាំងពង្រឹងការប្រមូលព័ត៌មាន និងការវិភាគ ដើម្បីជួយគាំទ្រដល់ការវាយតម្លៃនៅថ្នាក់រដ្ឋបាលកណ្តាល និងថ្នាក់ខេត្ត-ក្រុង ។
- ពង្រឹងការកសាងសមត្ថភាពក្នុងការកែលំអការបង្រៀន និងរៀននៅតាមសាលារៀន ជាពិសេសនៅតំបន់ដាច់ស្រយាល តំបន់ព្រំដែន និងតំបន់ជួបការលំបាក ។
- ពង្រឹងការកសាងសមត្ថភាពក្នុងការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ និងការធ្វើរបាយការណ៍នៅគ្រប់លំដាប់ថ្នាក់ ។

ពង្រឹងគុណភាពនៃការពិនិត្យតាមដានការបំពេញការងាររបស់សាលារៀន តាមរយៈបង្កើនការចូលរួមពីសហគមន៍ ។